ការស្វែងយល់អំពីជីវិត

# គ្មានការភ័យខ្លាច
## ចំពោះសេចក្ដីស្លាប់ទៀតឡើយ





# គ្មានការភ័យខ្លាច

## ចំពោះសេចក្ដីស្លាប់ទៀតឡើយ

### “គ្មាននរណាម្នាក់ ចង់ជួបសេចក្ដីស្លាប់នោះទេ”

**មានរឿងតិចណាស់ ដែលគួរឲ្យភ័យខ្លាច** ជាងសេចក្ដីស្លាប់។ ស្រមោលនៃសេចក្ដីស្លាប់ មានសន្ទុះរីកធំឡើង គ្របដណ្ដប់លើការរស់នៅរបស់យើង ដោយរំឭកយើងថា អ្វីគ្រប់យ៉ាងដែលយើងកំពុងត្រេកអរសប្បាយ អាចនឹងត្រូវបាត់បង់ ក្នុងពេលតែមួយប៉ប្រិចភ្នែក។ ទោះការបាត់បង់នោះ កើតឡើងដោយសារជំងឺ ឬដោយសារគ្រោះថ្នាក់ណាមួយ ឬក៏ដោយសារវ័យចាស់ជរាក្ដី យើងទាំងអស់គ្នា សុទ្ធតែត្រូវស្លាប់នៅពេលណាមួយ ដោយមិនអាចជៀសផុត។ អ្នកខ្លះបានត្រៀមខ្លួនជាស្រេច សម្រាប់ការស្លាប់ ខណៈពេលដែលមានមនុស្សតិចតួច ដែលចង់ឲ្យសេចក្ដីស្លាប់ឆាប់មក ប៉ុន្តែ មនុស្សភាគច្រើនខ្លាចសេចក្ដីស្លាប់។ នេះគឺជារឿងធម្មតាទេ ដែលមនុស្សភាគច្រើន ស្ទើរតែមិនអាចយកឈ្នះលើការភ័យខ្លាច ចំពោះសេចក្ដីស្លាប់ បានទាំងស្រុង។ នោះគឺដោយព្រោះតែយើងមិនអាចរកឃើញមធ្យោបាយ ដើម្បីយកជ័យជំនះលើសេចក្ដីស្លាប់ ឬរកផ្លូវគេចផុតពីវាបានឡើយ។ បើ អ្នកខ្លាចសេចក្ដីស្លាប់ នោះសូមកុំអស់សង្ឃឹមឡើយ ព្រោះមិនមែនមានតែអ្នកទេ ដែលមានអារម្មណ៍បែបនេះ។

លោកស្ទីវ ចប(Steve Jobs) ដែលជាស្ថាបនិក ក្រុមហ៊ុន Apple និងជាអ្នកផ្ដើមគំនិតបង្កើតទូរស័ព្ទ ម៉ាក iPhone បានមានប្រសាសន៍ នៅក្នុងការថ្លែងសន្ទរកថា ក្នុងឆ្នាំ២០០៥ ថា “គ្មានមនុស្សណាម្នាក់ ចង់ស្លាប់ទេ។ សូម្បីតែមនុស្ស ដែលចង់ទៅស្ថានសួគ៌ ក៏មិនចង់ឆ្លងកាត់ការស្លាប់ ដើម្បីឲ្យបានទៅនៅទីនោះដែរ។

លោកចបបានដឹងច្បាស់ថា ខ្លួនគាត់កំពុងនិយាយពីអ្វី ពីព្រោះគាត់បានពិនិត្យសុខភាពឃើញ មានជំងឺមហារីកលំពែង ហើយពេទ្យបានប្រាប់គាត់ថា គាត់អាចរស់បានត្រឹមតែ រយៈពេលបី ទៅប្រាំមួយខែទៀតប៉ុណ្ណោះ។ តាមរយៈប្រតិកម្មដាដំបូង ដែលគាត់មានចំពោះដំណឹងដ៏អាក្រក់នោះ យើងអាចដឹងថា គាត់មានអារម្មណ៍យ៉ាងណានៅពេលនោះ។ គាត់ក៏បានរំឭកផងដែរថា "នៅថ្ងៃនោះ បន្ទាប់ពីជួបគ្រូពេទ្យហើយ ខ្ញុំបានគិតអំពីជម្ងឺរបស់ខ្ញុំ ពេញមួយថ្ងៃ"។ លោកស្ទីវ ចបក៏បានទទួលមរណភាព នៅឆ្នាំ២០១១។

*សេចក្តីស្លាប់តំណាងឲ្យចុងបញ្ចប់។* ជាការពិតណាស់ ការស្លាប់គឺជាការឈានដល់ដំណាក់កាលចុងក្រោយនៃជីវិត ដែលជាសម្គាល់ឲ្យយើងដឹងថា ពេលវេលារបស់យើង នៅលើផែនដីនេះដល់ទីបញ្ចប់ហើយ ហើយយើងនឹងលែងមានឱកាសធ្វើអ្វីមួយ ដើម្បីសម្រេចក្តីសង្ឃឹម និងក្តីស្រមៃ ហើយក៏លែងមានឱកាសលប់លាងទោសកំហុសរបស់យើងទៀត។

*សេចក្តីស្លាប់តំណាងឲ្យ ការបាត់បង់ចុងក្រោយបំផុត។* ពេលដែលការស្លាប់មកដល់ យើងនឹងមិនត្រឹមតែបាត់បង់រូបរាងកាយរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងត្រូវបាត់បង់ទាំងអត្តសញ្ញាណ និងកិត្តិយស ព្រមទាំងអ្វីៗទាំងអស់ដែលសំខាន់ ក្នុងជីវិតយើង។ មិនតែប៉ុណ្ណោះ សេចក្តីស្លាប់ពង្រាត់យើង ឲ្យឃ្លាតឆ្ងាយពី មនុស្សជាទីស្រលាញ់របស់យើង ដោយឲ្យយើងចាកចេញពីពួកគេ ដោយបន្សល់ទុកនូវអនុស្សាវរីយ៍។ ទោះបីជាយើងបានប្រុងប្រៀបខ្លួនរួចជាស្រេចសម្រាប់ការស្លាប់របស់យើង ក៏យើងនៅតែមានការព្រួយបារម្ភ អំពីមនុស្សដែលនៅរស់ ហើយក៏ខ្លាចគ្មានមាននរណាមើលថែពួកគេ ពេលដែលវត្តមានរបស់យើងបាត់ពីផែនដីនេះទៅ។

*សេចក្តីស្លាប់តំណាងឲ្យការអ្វីដែលយើងមិនដឹង។* ក្រោយដែលយើងស្លាប់ហើយ តើនៅមានអ្វីបន្ទាប់ទៀត? តើនឹងមានអ្វីកើតឡើងហើយតើយើងនឹងត្រូវជួបនរណា? តើពិតជាមានស្ថានសួគ៌ ឬស្ថាននរកមែនឬ? តើយើងនឹងត្រូវជួបព្រះជាម្ចាស់ ដើម្បីទទួលខុសត្រូវចំពោះការអ្វីដែលយើងបានប្រព្រឹត្តឬ? មុនពេលដែលការស្លាប់ជិតមកដល់ អ្នកខ្លះប្រហែលជាទន្ទឹងរង់ចាំអ្វីដែលខ្លួនមិនដឹង ប៉ុន្តែ មនុស្ស

ភាគច្រើននឹងមានការថប់បារម្ភ។ អ្វីកាន់តែអាក្រក់ជាងនេះទៀតនោះ គឺយើងត្រូវឆ្លងកាត់ដំណាក់កាលដ៏គួរឲ្យភ័យខ្លាច នៃការស្លាប់ តែម្នាក់ឯងគត់។ បានសេចក្តីថា គ្មាននរណាម្នាក់អាចអមដំណើរយើង ចូលទៅក្នុងសេចក្តីស្លាប់ ជាមួយយើងបានឡើយ។

មានពាក្យស្លោករបស់ចិនមួយឃ្លា ដែលបាននិយាយសរុបសេចក្តីនេះយ៉ាងខ្លីថា "ជីវិតប្រៀបដូចជាចំហាយទឹក ដែលរលាយបាត់ ក្នុងពេលតែមួយប៉ប្រិចភ្នែក"។ នៅពេលដែលសេចក្តីស្លាប់ចូលមកដល់ វាក៏បានដកអ្វីៗដែលយើងធ្លាប់មាន និងសម្រេចបាន ចេញពីយើង ហើយមើលទៅជីវិតយើងហាក់ដូចជាខ្លីណាស់ ប្រៀបដូចជាចំហាយទឹក ដែលត្រូវសូន្យបាត់ ដោយសារកម្តៅថ្ងៃតែបន្តិច។

## ការតយុទ្ធដ៏ស្វិតស្វាញរបស់មនុស្ស ប្រឆាំងនឹងសេចក្តីស្លាប់

**លោក អឺននេស បេកខើរ** (Earnest Becker) ជានរវិទូ ផ្នែកវប្បធម៌ បាននិពន្ធសៀវភៅមួយក្បាល មានចំណងជើងថា *ការបដិសេធន៍សេចក្តីស្លាប់។* ក្នុងសៀវភៅ ដែលបានទទួលពានរង្វាន់នោះ គាត់បានសង្កេតឃើញថា មនុស្សយើងខិតខំធ្វើអ្វីៗជាច្រើន ដោយសារយើងមានការភ័យខ្លាចចំពោះសេចក្តីស្លាប់។ គាត់បានសរសេរក្នុងសៀវភៅនោះថា "ការភ័យខ្លាចចំពោះសេចក្តីស្លាប់ បានតាមលងបន្លាចជីវិតមនុស្ស លើសអ្វីទាំងអស់។ ការភ័យខ្លាចចំពោះសេចក្តីស្លាប់ ជាកត្តាជំរុញឲ្យមនុស្សធ្វើសម្មភាព គឺសកម្មភាព ដែលបានធ្វើឡើង ក្នុងបំណងជាចម្បង ដើម្បីគេចចេញពីសេចក្តីស្លាប់ និងដើម្បីយកឈ្នះលើការស្លាប់ ដោយបដិសេធន៍ថា វាមិនមែនជាគោលដៅចុងក្រោយរបស់មនុស្សទេ"។

គាត់ពិតជានិយាយត្រូវណាស់! ជានិច្ចកាល យើងតែងតែងខិតខំស្វែងរក ការព្យាបាល តាមបែបវេជ្ជសាស្ត្រ ដើម្បីប្រឆាំងនឹងផលវិបាកនៃភាពចាស់ជរា និងពន្យាជីវិតរបស់យើង។ យើងក៏បានព្យាយាម ធ្វើយ៉ាងណា ឲ្យកេរដំណែលរបស់ខ្លួន នៅជាប់ជារហូត ដោយខិតខំថែរក្សាសមិទ្ធផល និងសាងសង់វិមានរំឭក សម្រាប់កូនចៅជំនាន់ក្រោយ

ដោយសង្ឃឹមថា គេនឹងមិនបំភ្លេចយើងឡើយ។ ពុំនោះទេ មនុស្សយើងក៏បានព្យាយាមបដិសេធវត្តមាននៃសេចក្តីស្លាប់ ដោយខំប្រឹងផ្តោតចិត្តទៅលើការរស់នៅ ឲ្យបានសប្បាយបំផុត ដែលនោះជាគោលការណ៍ដែលមានក្នុងពាក្យស្លោករបស់លោកិយ ដែលបានពោលថា "ចូរបរិភោគ ស៊ីផឹក ហើយសប្បាយរីករាយចុះ ព្រោះថ្ងៃស្អែក យើងនឹងស្លាប់ហើយ"។

វិធីសាស្ត្រទាំងនេះ ហាក់ដូចជាមានភាពគ្រប់គ្រាន់ សម្រាប់មនុស្សមួយចំនួន តែមនុស្សភាគច្រើននៅតែពិបាកដកចេញនូវការភ័យខ្លាចដ៏ជ្រៅបំផុត ដែលយើងមានចំពោះសេចក្តីស្លាប់។ ទោះយើងបានព្យាយាមបដិសេធសេចក្តីស្លាប់ ឬព្យាយាមឈប់គិតពីវា យ៉ាងណាក៏ដោយ ក៏យើងនៅតែមិនបានត្រៀមខ្លួន សម្រាប់ការស្លាប់ដដែល។ យើងប្រហែលជាបានព្យាយាមធ្វើអ្វីគ្រប់យ៉ាង តាមដែលអាចធ្វើទៅបាន ដើម្បីរៀបចំខ្លួនយើង និងគ្រួសាររបស់យើង សម្រាប់ការស្លាប់របស់យើង ប៉ុន្តែ នៅពេលដែលយើងដឹងថា ការស្លាប់បង្ហាញខ្លួនកាន់តែច្បាស់នៅចំពោះយើង នៅពេលដែលពេទ្យប្រាប់យើងថា យើងមានជម្ងឺដែលនឹងត្រូវស្លាប់ក្នុងពេលដ៏ឆាប់ខាងមុខ នោះយើងនឹងពិបាកសម្លឹងមើលទៅសេចក្តីស្លាប់ឲ្យចំមុខ ហើយក៏ពិបាកនិយាយថា "ខ្ញុំបានត្រៀមខ្លួនរួចហើយ"។

> **ទោះយើងបានព្យាយាមបដិសេធសេចក្តីស្លាប់ ឬព្យាយាមឈប់គិតពីវា យ៉ាងណាក៏ដោយ ក៏យើងនៅតែមិនបានត្រៀមខ្លួន សម្រាប់ការស្លាប់ដដែល។**

ហេតុអ្វីបានជាយើងមានការពិបាកយ៉ាងនេះ? ការភ័យខ្លាចនេះ គឺមានប្រភពនៃនៅក្នុងនិស្ស័យសាច់ឈាមរបស់យើង ដែលជាមនុស្ស។ សេចក្តីស្លាប់បានទាស់ប្រឆាំង នឹងសភាវគតិរបស់យើង ដែលចង់តែរស់។ វាជាតំណាងឲ្យភាពងងឹត និងភាពទទេ។ ក្នុងរឿងនេះយើងពិបាកនឹងធ្វើចិត្ត កុំឲ្យខ្លាចបាត់បង់អ្វីៗដែលយើងមាន និងកុំឲ្យខ្លាចឃ្លាតឆ្ងាយពីរូបកាយ និងមនុស្សជាទីស្រលាញ់ ជារៀងរហូត។ គ្មានថ្នាំណា ផែនការណា ឬការគិតបែបវិជ្ជមានណា ដែលអាចលុបបំបាត់ស្រមោលនៃសេចក្តីស្លាប់ ដែលបានតោងជាប់យើង

ម្នាក់ៗនោះឡើយ។

ដូច្នេះ តើយើងត្រូវធ្វើដូចម្តេច? តើមានផ្លូវអ្វី សម្រាប់ឲ្យយើងគេចចេញពីសេចក្តីស្លាប់ និងផលប៉ះពាល់របស់វាឬទេ? តើយើងអាចរស់នៅជារៀងរហូតឬទេ? ក្នុងរឿងនេះ គ្រីស្ទបរិស័ទជឿថា យើងមានចម្លើយមួយ សម្រាប់សំណួរទាំងនេះ។

## មានតែព្រះយេស៊ូវមួយអង្គគត់ ដែលអាចយកឈ្នះសេចក្តីស្លាប់បាន

**ប្រមាណជា២០០០ឆ្នាំមុន** មានអង្គបុគ្គលមួយអង្គ ធ្វើដំណើរទៅកាន់តំបន់ជាច្រើន ហើយបង្រៀនគេថា "ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត"។ អង្គបុគ្គលនោះមានព្រះនាមថា យេស៊ូវ។ ទ្រង់បានអះអាងដោយភាពក្លាហានថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ ហើយទ្រង់ប្រកាសទៀតថា ទ្រង់នឹងឈ្នះសេចក្តីស្លាប់។ ពួកអ្នកស្អប់ទ្រង់ បានយកទ្រង់ទៅធ្វើគុត នៅលើឈើឆ្កាង ប៉ុន្តែ បីថ្ងៃក្រោយមក ទ្រង់បានមានព្រះជន្មរស់ឡើងវិញ[1]។ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញហើយ មានមនុស្សរាប់រយនាក់បានឃើញទ្រង់មានព្រះជន្មរស់ ហើយពីដំបូងអ្នកខ្លះមិនជឿថាទ្រង់មានព្រះជន្មរស់ឡើងវិញទេ តែក្រោយមក ពួកគេក៏បានឃើញទ្រង់មានព្រះជន្មរស់ផងដែរ។

ហេតុអ្វីបានជាព្រះយេស៊ូវអាចយកជ័យជម្នះលើសេចក្តីស្លាប់បាន? ព្រោះព្រះចេស្តារបស់ព្រះជាម្ចាស់ បានប្រោសទ្រង់ឲ្យមានព្រះជន្មរស់ឡើងវិញ។

រឿងនេះពិតជាសំខាន់ចំពោះយើងណាស់។ ព្រះគម្ពីរបានពន្យល់ថា ព្រះជាម្ចាស់បានបង្កើតយើងទាំងអស់គ្នាមក ឲ្យធ្វើមនុស្សមានសីលធម៌ ដូច្នេះហើយ ទ្រង់ក៏បានប្រទានឲ្យយើងមានសុភាវគតិឲ្យដឹងថា អ្វីត្រូវ អ្វីខុស។ ប៉ុន្តែ យើងមិនអាចធ្វើនូវទង្វើរដែលត្រឹមត្រូវឲ្យបានល្អឥតខ្ចោះ និងទៀងទាត់ឡើយ[2]។ នោះគឺដោយសារ យើងរាល់គ្នាជាមនុស្សមានបាប ដែលខ្វះមិនដល់សិរីល្អរបស់ព្រះ ឬមិនអាចបំពេញតាមខ្នាតគំរូ ឬស្តង់ដានៃភាពបរិសុទ្ធ និងក្រមសីលធម៌របស់ព្រះ[3]។ ហើយលទ្ធផលនៃអំពើបាប គឺជាសេចក្តីស្លាប់[4]។ ហេតុនោះហើយ

យើងទាំងអស់គ្នាសុទ្ធតែរស់នៅ ក្រោមបណ្តាសានៃសេចក្តីស្លាប់។ សេចក្តីស្លាប់នោះឯងដែលបានបំបែកយើង ឲ្យដាច់ចេញពីព្រះជាម្ចាស់ជារៀងរហូត។

ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវបានទទួលទោសនៃអំពើបាបទាំងអស់ ជំនួសយើងរាល់គ្នា។ ទោះទ្រង់គ្មានទោសសោះក៏ដោយ ក៏ទ្រង់បានសុគ្រព្រះទ័យសុគត ដើម្បីជួយសង្គ្រោះយើងរាល់គ្នា ដោយព្រះអង្គទ្រង់ដែលគ្មានបាបសោះ បានសុគតនៅលើឈើឆ្កាង ជំនួសមនុស្សមានបាបទាំងអស់។ ហើយការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ គឺជាភស្តុតាងបញ្ជាក់ថា ទ្រង់ពិតជាមានជ័យជម្នះលើអំពើបាប និងបណ្តាសានៃអំពើបាប ដែលជាសេចក្តីស្លាប់នោះឯង។

1 "ដ្បិតមុនដំបូង ខ្ញុំបានប្រាប់អ្នករាល់គ្នាតាមសេចក្តី ដែលខ្ញុំបានទទួលដែរ គឺថា ព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នាតាមបទគម្ពីរ។ ហើយទ្រង់ត្រូវបានគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ។ ហើយថា ទ្រង់បានលេចមកអោយកេផាសឃើញ រួចដល់ពួក១២នាក់ដែរ"។ ១ កូរិនថូស ១៥:៣-៥

2 "ដ្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អជានិច្ច ប៉ុន្តែ រកធ្វើមិនកើតសោះ។ ខ្ញុំមិនប្រព្រឹត្តការល្អ ដែលខ្ញុំចង់ធ្វើនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ នោះបែរជាខ្ញុំធ្វើវិញ។ រ៉ូម ៧:១៨-១៩

3 "ពីព្រោះគ្រប់គ្នា បានធ្វើបាប ហើយខ្វះមិនដល់សេរីល្អ នៃព្រះ។ រ៉ូម ៣:២៣

4 "ដ្បិតឈ្នួល នៃអំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតអស់កល្បជានិច្ច ដោយសារព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។ រ៉ូម ៦:២៣

## យើងក៏អាចមានជ័យជម្នះ លើសេចក្ដីស្លាប់ផងដែរ

**ដំណឹងល្អនោះគឺថា** ព្រះយេស៊ូវបានឲ្យយើងមានឱកាសឈ្នះអំពើបាប និងសេចក្ដីស្លាប់ ជាមួយទ្រង់ផងដែរ។ តើយើងអាចឈ្នះអំពើបាប និងសេចក្ដីស្លាប់ ជាមួយទ្រង់ ដោយរបៀបណា? គឺដោយទទួលជឿថា ទ្រង់បានសុគត់ជំនួសយើងរាល់គ្នា និងដោយការដើរតាមទ្រង់ ដោយទទួលទ្រង់ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃជីវិតរបស់យើងផ្ទាល់ខ្លួន ។ ព្រះគម្ពីរបានចែងថា “បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត” (រ៉ូម ១០:៩)។ ព្រះគម្ពីរក៏បានប្រាប់យើងផងដែរថា ព្រះទ្រង់មិនត្រឹមតែអត់ទោសបាបយើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងប្រទាននូវជីវិតអស់កល្បជានិច្ចដល់យើង ដើម្បីឲ្យយើងបានរស់នៅជាមួយនឹងទ្រង់ ជារៀងរហូត[5]។

ឧបមាថា មានសិស្សម្នាក់ត្រូវទៅជួបនាយកសាលា បន្ទាប់ពីខ្លួនបានធ្វើខុសបទបញ្ជាផ្ទៃក្នុងសាលា។ នៅពេលដែលគាត់ទៅដល់ការិយាល័យរបស់នាយកសាលា គាត់ក៏មានអារម្មណ៍ភ័យញ័រ ដោយគិតថា គាត់ប្រហែលជាត្រូវទទួលពិន័យហើយ។ ដោយសារគាត់ភ័យខ្លាចពេក គាត់មិនហ៊ានចូលទៅខាងក្នុងភ្លាមៗទេ ដូច្នេះហើយ គាត់ក៏បានឈរនៅខាងក្រៅមួយសន្ទុះសិន។

ព្រះយេស៊ូវបានឲ្យយើងមានឱកាសឈ្នះអំពើបាប និងសេចក្ដីស្លាប់ ជាមួយទ្រង់ផងដែរ។

បន្ទាប់មក គាត់ក៏បានឃើញក្មេងម្នាក់ទៀត ដើរចូល ក្នុង យ៉ាងមានទំនុកចិត្ត ហើយក៏បានដើរចេញមកវិញ ដោយទឹកមុខញញឹម។ គាត់ក៏សួរក្មេងប្រុសនោះថា “ហេតុអ្វីបានជាអ្នកមិនមានការភ័យខ្លាច នៅពេលដែលអ្នកដើរចូលទៅក្នុងការិយាល័យរបស់នាយកសាលា? តើហេតុអ្វីបានជាអ្នកអាចចេញមកក្រៅវិញ ដោយទឹកមុខរីករាយយ៉ាងនេះ?” ក្មេងប្រុសនោះក៏បានមើលមុខគាត់ ហើយក៏តបមកវិញថា “ពីព្រោះលោកនាយក គឺជាឪពុករបស់ខ្ញុំ”។

នៅពេលដែលយើងទទួលជឿព្រះយេស៊ូវ យើងនឹងបានដូចជាក្មេងប្រុសទីពីរ ពោលគឺយើងគ្មានការភ័យខ្លាច ចំពោះសេចក្ដីស្លាប់ទៀតឡើយ។ ទោះយើងនឹងត្រូវស្លាប់ខាងរូបកាយមែន ព្រះទ្រង់នៅរង់ចាំទទួលយើង បន្ទាប់ពីយើងស្លាប់ទៅ។ ដូច្នេះហើយ យើងមិនចាំបាច់ត្រូវខ្លាចការជំនុំជម្រះរបស់ទ្រង់ទៀតឡើយ។ យើងនឹងចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ យ៉ាងពេញលេញ ព្រមទាំងបានអរសប្បាយក្នុងការប្រកបស្និទ្ធស្នាលអស់កល្បជានិច្ច ជាមួយទ្រង់ ដែលជាព្រះដែលបានបង្កើតយើងមក ដោយមានសេរីភាពរួចពីការឈឺចាប់ និងសេចក្ដីសោកសង្រេង។[6]

ក្នុងនាមជាអ្នកជឿព្រះយេស៊ូវ យើងនឹងមិនប្រឈមមុខ ចំពោះសេចក្ដីស្លាប់ តែម្នាក់ឯងឡើយ។ តើហេតុអ្វី? ពីព្រោះព្រះយេស៊ូវ នឹងអមដំណើរជាមួយយើង ឆ្លងកាត់សេចក្ដីស្លាប់។ ក្នុងនាមទ្រង់ជាព្រះរាជបុត្រានៃព្រះ ដែលបានសុគត ហើយឈ្នះសេចក្ដីស្លាប់ ទ្រង់ក៏អាចដើរជាមួយយើង ពេញមួយជីវិតរបស់យើង និងដរាបដល់ទីបញ្ចប់ផង។ ក្រុមគ្រួសារ និងមិត្តភក្តិរបស់យើងអាចរួមដំណើរជាមួយយើង បានតែនៅពេលដែលយើងរស់នៅប៉ុណ្ណោះ ប៉ុន្តែ យ៉ាងណាក៏ដោយ យើងនឹងត្រូវចាកចេញពីពួកគេ នៅពេលដែលយើងស្លាប់ទៅ។ មានតែព្រះយេស៊ូវមួយអង្គគត់ ដែលអាចនៅក្បែរយើងជាប់ជានិច្ច នៅពេលដែលយើងឆ្លងកាត់សេចក្ដីស្លាប់ ដោយកាន់ដៃយើងជាប់ ខណៈពេលដែលយើងត្រូវធ្វើដំណើរនៅក្នុងជីវិតនេះ ហើយឆ្លងកាត់សេចក្ដីស្លាប់ រួចចូលក្នុងជីវិតអស់កល្បជានិច្ចជាមួយទ្រង់។

យើងអាចមានសេចក្ដីសង្ឃឹម ចំពោះព្រះបន្ទូលសន្យានេះបានពីព្រោះនេះជាព្រះបន្ទូលសន្យា ដែលចេញមកពីព្រះយេស៊ូវដោយផ្ទាល់។ ទ្រង់ជាព្រះរាជបុត្រានៃព្រះ ដែលបានយកជ័យជម្នះលើសេចក្ដីស្លាប់រួចហើយ។

## គ្មានការភ័យខ្លាច ទៀតឡើយ

**តើអ្នកមានការថប់បារម្ភអំពីការស្លាប់** ហើយព្រួយបារម្ភ អំពីរឿងដែលនឹងកើតឡើងចំពោះអ្នក បន្ទាប់ពីការស្លាប់ឬទេ? តើការព្រួយបារម្ភនេះបានធ្វើអ្នកមានអារម្មណ៍ពិបាកពេកឬ? តើអ្នកមានការលំបាក ក្នុងការ

ប្រឈមមុខចំពោះសេចក្តីស្លាប់ ដែលមិនអាចជៀសរួចឬ?

សូមងាកមករកព្រះយេស៊ូវ ដើម្បីទទួលយកនូវដំណោះស្រាយសម្រាប់បញ្ហានេះ។ ដ្បិតទ្រង់បានឈ្នះសេចក្តីស្លាប់ ព្រមទាំងបានបង្ហាញព្រះចេស្តា ដែលឈ្នះអំពើបាប និងសេចក្តីស្លាប់ ដែលជាលទ្ធផលនៃអំពើបាប។ អ្នកនឹងមានជ័យជម្នះ មកលើសេចក្តីស្លាប់ និងអំពើបាបជាមួយទ្រង់ផងដែរ ប្រសិនបើអ្នកជឿថា ទ្រង់បានសុគតជំនួសអ្នក ហើយជឿថា ទ្រង់មានព្រះជន្មរស់ឡើងវិញ ព្រមទាំងជឿលើព្រះបន្ទូល ដែលទ្រង់បានសន្យាថា ទ្រង់នឹងប្រទានជីវិតអស់កល្បជានិច្ចដល់អ្នក។

បើអ្នកបានជឿព្រះយេស៊ូវហើយ នោះអ្នកនឹងមិនចាំបាច់ត្រូវភ័យខ្លាច ចំពោះសេចក្តីស្លាប់ និងចំពោះការអ្វីដែលនឹងកើតឡើងចំពោះអ្នក បន្ទាប់ពីអ្នកស្លាប់នោះឡើយ។ ផ្ទុយទៅវិញ អ្នកនឹងអាចរស់នៅ ក្នុងសេចក្តីសង្ឃឹម ដោយដឹងច្បាស់ថា ក្រោយពេលដែលរូបកាយរបស់អ្នកស្លាប់ទៅ អ្នកនឹងបន្តរស់នៅ ជាមួយនឹងព្រះអង្គជារៀងរហូត។ នៅពេលនោះ អ្នកនឹងបានអរសប្បាយ ក្នុងការទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយព្រះអង្គ ជារៀងរហូតទៅ។ អ្នកនឹងមិនចាំបាច់ភ័យខ្លាច ថានឹងត្រូវស្លាប់តែម្នាក់ឯងទៀតទេ ព្រោះអ្នកអាចដឹងច្បាស់ថា ព្រះយេស៊ូវនឹងធ្វើដំណើរជាមួយអ្នកជិតបង្កើយ ទាំងក្នុងពេលដែលអ្នកនៅមានជីវិតរស់នៅ និងក្នុងពេលដែលអ្នកត្រូវឆ្លងកាត់សេចក្តីស្លាប់ ហើយរហូតទៅដល់ពេលដែលត្រូវចូលទៅ ក្នុងជីវិតអស់កល្បជានិច្ច។

5 ˝ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ˝។ យ៉ូហាន ៣:៦

6 ˝កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ខ្ញុំដែរ។ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា។ បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ។ ឯកន្លែងដែលខ្ញុំទៅ នោះអ្នករាល់គ្នាក៏ដឹង ហើយក៏ស្គាល់ផ្លូវទៅដែរ។ ... ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ˝។ យ៉ូហាន ១៤:១-៤,៦

## តើអ្នកចង់ងាកមករកព្រះយេស៊ូវដែរឬទេ?

**ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែម** អំពីព្រះយេស៊ូវ ហើយចង់ដឹងពីរបៀបឈ្នះអំពើបាប និងសេចក្តីស្លាប់ ជាមួយទ្រង់ សូមទំនាក់ទំនងជាមួយព្រះវិហារ ដែលនៅជិតលោកអ្នក នៅទីនោះនឹងមានមនុស្សដែលអាចឆ្លើយសំណួរ ដែលអ្នកមាន។ ហើយម្យ៉ាងទៀត សូមស្វែងរកព្រះគម្ពីរប៊ីបមួយក្បាល សម្រាប់អាន។ ព្រះគម្ពីរប៊ីបអាចនិយាយប្រាប់អ្នកអំពីព្រះជាម្ចាស់ និងអំពីរបៀបដែលទ្រង់អាចប្រទានការកម្សាន្តចិត្ត និងសន្តិភាពដែលអ្នកត្រូវការ។

យើងខ្ញុំ នៅអង្គការនំម៉ាណាប្រចាំថ្ងៃ ក៏រីករាយនឹងជួយឲ្យអ្នកស្វែងរកព្រះយេស៊ូវ ហើយរកបានសេចក្តីសង្ឃឹម ដែលទ្រង់ប្រទាន។ ប្រសិនបើអ្នកចង់អានសៀវភៅផ្សេងទៀត ដែលទាក់ទងនឹងព្រះគម្ពីរ សូមចូលទៅកាន់វេបសាយរបស់យើងខ្ញុំ ដែលមានអាស័យដ្ឋាន www.khmer-odb.org។

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក លី ប៊ុនថា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries (website: www.odb.org)

ចេញផ្សាយដោយ : ODB Cambodia (email: cambodia@odb.org, Tell: 087 233 907, website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb)